**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧០ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារកម្ពុជា ប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩២ និង ផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញអនុសញ្ញាស្តីពី សិទ្ធិកុមារ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩២ និងផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី ។

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារកម្ពុជា (Cambodian COMMIT Task force) ប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ ដោយមានសមាសភាពដូចខាងក្រោម :

១- លោកជំទាវ **យូ អយ** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ប្រធាន

២- ឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ អនុប្រធាន

៣- លោក **ឌួច សាម៉ុន** អគ្គនាយករង អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អនុប្រធាន

៤- លោកជំទាវ **សាន្ត អរុណា** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី សមាជិក

៥- ឯកឧត្តម **អៀ ម៉េងទ្រី** អនុប្រធានគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍន៍ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦- លោកស្រីឧត្តមសេនីយ៍ត្រី **អ៊ុន សុគន្ធា** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

៧- ឧត្តមសេនីយ៍ត្រី **អ៊ុច សំណាង** នាយរងសេនាធិការ នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៨- លោក **យ៉េង ទ័ន** ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ សមាជិក

៩- លោកស្រី **ញឹម ច័ាន់ចន្ទគន** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងអប់រំ យុវជន និង កីឡា សមាជិក

១០-លោក **គីម សុវណ្ណា** អនុប្រធាននាយកដ្ឋានច្បាប់ និង កុងស៊ុល ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សមាជិក

១១-លោកស្រី **ហេង ស៊ីផុន** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួងកិច្ចការនារី លេខាធិការអចិន្ត្រៃយ៍

ក្រុមការងារកម្ពុជានេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ស្ថិតនៅនាយកដ្ឋានការពារផ្លូវច្បាប់ នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម នៃក្រសួងកិច្ចការនារី ។ ក្រុមការងារកម្ពុជានេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី ដើម្បីដំណើរការការងារ ។

**ប្រការ ២._**

ក្រុមការងារកម្ពុជាមានភារកិច្ចដូចតទៅ :

- សហការជាមួយលេខាធិការដ្ឋាន គំរោងអន្តរភ្នាក់ងារសហប្រជាជាតិស្តីពី ការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ UN Inter-Agency Project on Human Trafficking in the greater Mekong Sub-Region (UNIAP-C) ប្រចាំកម្ពុជា ប្រចាំទីក្រុងបាងកក និងជាមួយបណ្តាដៃគូដទៃទៀត ក្នុងការសម្របសម្រួលរាល់សកម្មភាពថ្នាក់ជាតិ និងថ្នាក់តំបន់
- រៀបចំផែនការសកម្មភាពថ្នាក់មហាអនុតំបន់ ឆ្នាំ២០០៥-២០០៧ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ពិសេសការជួញដូរស្ត្រី និង កុមារ ដោយប្រមូលផ្តុំនូវកិច្ចខិតខំប្រឹងប្រែងចាំបាច់នានាដើម្បីប្រែក្លាយផែនការសកម្មភាពនេះជាការអនុវត្តជាក់ស្តែង
- ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គអោយបានពេញលេញ និង មានប្រសិទ្ធភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់មហាអនុតំបន់ និងជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ និង អង្គការអន្តរជាតិក្នុងការគៀងគរជំនួយដើម្បីអនុវត្តផែនការសកម្មភាពមហាអនុតំបន់
- ពិនិត្យតាមដាននិងវាយតម្លៃ ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ និង រាយការណ៍ជូនរាជរដ្ឋាភិបាល
- ពិនិត្យឡើងវិញនូវការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គរៀងរាល់ ៣ ឆ្នាំម្តង ហើយរាយការណ៍ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣._**

ក្រុមការងារកម្ពុជា មានសិទ្ធិស្នើសុំជំនួយបច្ចេកទេស អ្នកជំនាញការអន្តរជាតិតាមការចាំបាច់ដើម្បីជួយបណ្តុះបណ្តាល និងជួយតាមដាន វាយតម្លៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ។

**ប្រការ ៤._**

សមាជិកក្រុមការងារកម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីចាំបាច់ ប្រធានក្រុមការងារអាចអញ្ជើញតំណាងក្រសួងពាក់ព័ន្ធចូលរួមប្រជុំ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងពាក់ព័ន្ធ និង បណ្ដាសមាសភាពដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ